### ២.២.១- មណ្ឌលផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ (VCCT)

នៅក្នុងត្រីមាសទី៣ ឆ្នាំ ២០០៦ មានអតិថិជនចំនួន ៥៥,៥៨៦នាក់ បានមកធ្វើតេស្តឈាមរកមេរោគអេដស៍ នៅមណ្ឌល VCCT(**តារាងទី៣**), ជាសរុប ពីខែ មករា ដល់ខែ កញ្ញា ឆ្នាំ ២០០៦ មានអតិថិជន ចំនួន ១៥៤.៣២៤នាក់ ដែលបានមកធ្វើ តេស្តឈាមរកមេរោគអេដស៍។ ចំនួនសរុបនៃអតិថិជនដែលបានមកធ្វើតេស្តក្នុងត្រីមាសទី ៣ ឆ្នាំ ២០០៦, មានអតិថិជន ៣០,៥៥២នាក់ (៥៥.០%) ជាស្ត្រី។

| | **អតិថិជនបានធ្វើតេស្តរកមេរោគអេដស៍**<br>N= 55,586<br>No. (%) | **អតិថិជនបានធ្វើតេស្តរកមេរោគអេដស៍ លទ្ធផលវិជ្ជមាន**<br>N=4,239<br>No. (%) |
|---|---|---|
| **អាយុ** | | |
| ≤14 ឆ្នាំ | 3,023 (5.5) | 387 (9.1) |
| 15-49 ឆ្នាំ | 49,603 (89.2) | 3,614 (85.3) |
| > 49 ឆ្នាំ | 2,960 (5.3) | 238 (5.6) |
| **ភេទ** | | |
| ប្រុស | 26,034 (45.1) | 1,919 (45.3) |
| ស្រី | 30,552 (55.0) | 2,320 (54.7) |

***តារាងទី ៣:*** *លក្ខណៈនៃអតិថិជនដែលបានធ្វើតេស្តឈាមរកមេរោគអេដស៍នៅសេវា VCCT ក្នុងត្រីមាសទី ៣ ឆ្នាំ ២០០៦*

សេវា PITC ត្រូវបានឯកភាពយល់ព្រមក្នុងឯកសារគោលការណ៍ ដែលបានចុះហត្ថលេខាដោយក្រសួងសុខាភិបាល ក្នុងខែ កញ្ញា ឆ្នាំ២០០៦ នៅមណ្ឌលសុខភាពទាំងអស់ដែលមានសេវា VCCT ។ បុគ្គលិកសុខាភិបាលអាចស្នើសុំធ្វើ

តេស្តរកមេរោគ អេដស៍ចំពោះអ្នកណាម្នាក់ ដែលបានមកកាន់មណ្ឌលសុខភាព, ផ្តល់ពត៌មានមុនពេលធ្វើតេស្ត និងចេញលិខិតបញ្ជាក់ដើម្បីចូល ទៅកាន់សេវា VCCT ។ ការធ្វើតេស្តរកមេរោគអេដស៍ ត្រូវធ្វើនៅសេវា VCCT ដូចជាការផ្តល់ប្រឹក្សាក្រោយធ្វើតេស្ត ។

នៅស្រុកកោះធំ/ខេត្តកណ្តាល បានចាប់ផ្តើមអនុវត្តន៍ PITC ក្នុងខែសីហា ឆ្នាំ២០០៦ ដែលមានការកើនឡើងនៅសេវា VCCT ៩៥% ( ប្រជាជន ៦៣៩នាក់ បានធ្វើតេស្តក្នុងត្រីមាសទី ៣ ឆ្នាំ២០០៦ ផ្ទុយពីត្រីមាសទី ២ ឆ្នាំ២០០៦ មានតែ ៣២៨នាក់ ) ។

នៅត្រីមាសទី៦ ឆ្នាំ ២០០៦ , ៩៩.៨%( ចន្លោះពី ៨៤,៧%-១០០% នៅគ្រប់សេវា VCCT ទាំងអស់) នៃអតិថិជន VCCT ដែលបានទទួលការប្រឹក្សាលើកដំបូង ហើយបានធ្វើតេស្តឈាមរកមេរោគអេដស៍, ៩៨.៦% ( ចន្លោះពី ៨៣.២%-១០០% នៅ គ្រប់សេវា VCCT ទាំងអស់) នៃការធ្វើតេស្តនោះ គេបានទទួលលទ្ធផលតាមរយៈការផ្តល់ប្រឹក្សាមុនពេលទទួលលទ្ធផលតេស្ត (**រូបទី៤**) ។ ការកើនឡើងនេះ ឆ្លើយតបនិងការខិតខំប្រឹងប្រែង នឹងគោលបំណងដ៏ធំគឺ ចំនួន ៩៨% នៃប្រជាជនដែលបានទទួលការផ្តល់ប្រឹក្សាមុនពេលទទួលលទ្ធផលតេស្ត បានសំរេចតាមទិសដៅ ( **ឧបសម្ព័ន:VCCT អាំងឌីកាទ័រ ៣**) ។




***រូបទី ៣:*** *ចំនួនអតិថិជនដែលបានធ្វើតេស្តឈាមនៅមណ្ឌល VCCT (cascade) ក្នុងត្រីមាសទី ៣ ឆ្នាំ ២០០៦*

នៅក្នុងត្រីមាសនេះមានអតិថិជន VCCT ចំនួន ៣,៤១៤នាក់ (៦.១%) ត្រូវបានបញ្ជូនមកពីកម្មវិធីកំចាត់ជំងឺរបេង ផ្ទុយពីត្រីមាសមុន មានត្រឹមតែ ២,៦៧៣នាក់ (៥.៦%)(**រូបទី៥**) ។ នេះគឺជាសញ្ញាណនៃការកើនឡើង នូវចំនួនអ្នកជំងឺរបេងនៅ សេវា VCCT និងសូមថ្លែងអំណរគុណ ចំពោះសកម្មភាពចូលរួមសហការណ៏កម្មវិធីរបេង/អេដស៍ ។




***រូបទី ៤:*** *និន្នាការនៃចំពួនអតិថិជនVCCT ដែលត្រូវបានបញ្ជូនមកធ្វើតេស្តឈាម ដោយកម្មវិធីរបេង ក្នុងឆ្នាំ២០០៦*

អាត្រាប្រេវ៉ាឡង់ HIV ក្នុងចំណោមអតិថិជនដែលបានមកពិនិត្យឈាមនៅសេវា VCCT មានស្ថេរភាពត្រឹម ៧.៦%នៃអតិថិជន VCCT បានរកឃើញមានឆ្លងមេរោគអេដស៍ នាក្នុងត្រីមាសទី៣ ឆ្នាំ២០០៦ (**រូបទី៦**) ។




***រូបទី ៥:** និន្នាការនៃអត្រាប្រេវ៉ាឡង់HIV ក្នុងចំណោមអតិថិជនVCCT ពីត្រីមាសទី ១-២០០៥ ដល់ត្រីមាសទី ២-២០០៦*

## ២.២.២- អ្នកជំងឺឱកាសនិយម និងអ្នកជំងឺព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (OI and ART)

បច្ចុប្បន្ននេះ មានចំនួនអ្នកជំងឺសកម្មទាំងអស់ ១៨,២៥៦នាក់, ក្នុងនោះមាន ១៦,៦៨៥នាក់ ជាមនុស្សពេញវ័យ និង ១,៥៧១ នាក់ ជាកុមារកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (ART)(**រូបទី ៧,៨**) (**ឧបសម្ព័ន៖ HFBC អាំងឌីកាទ័រ ៣**) ។




***រូបទី ៦:** និន្នាការនៃអ្នកជំងឺអេដស៍ សកម្ម ដែលបានទទួលការព្យាបាលដោយ ART ពីត្រីមាសទី ១-២០០៥ ដល់ត្រីមាសទី ៣-២០០៦*




***រូបទី ៧:*** *និន្នាការចំនួនមនុស្សពេញវ័យ និងកុមារ សកម្ម ដែលកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (ART) ពីត្រីមាសទី ៣ ឆ្នាំ ២00៥ ដល់ត្រីមាសទី ៣ ឆ្នាំ ២00៦*

អ្នកជំងឺជាស្ត្រីមាន ៤៩.៣% នៃចំនួនអ្នកជំងឺសរុបទាំងអស់ ដែលបានទទួលការព្យាបាលដោយឱសថប្រឆាំងរោគអេដស៍ (ARV) នឹងមាន ៥0,៥% ទៀតជាមនុស្សពេញវ័យ ។

នៅតាមសេវាព្យាបាលជំងឺឱកាសនិយម/សេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (OI/ART Sites) អ្នកជំងឺថ្មីចំនួន ៣,៤៥0នាក់ បានចាប់ផ្តើមមកទទួលការពិនិត្យ-ព្យាបាលបង្ការជំងឺឱកាសនិយម(Pre-ART) និងអ្នកជំងឺថ្មីចំនួន ២,៤២៤នាក់ (បន្ថែម ១៨0នាក់ជាកុមារ) បានចាប់ផ្តើមទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (ART) នៅត្រីមាសទី ៣ ឆ្នាំ ២00៦ (**រូបទី៩**) ។ ជាមធ្យមមានអ្នកជំងឺដែលបានមកចុះឈ្មោះថ្មី ដើម្បីទទួលឱសថបង្ការជំងឺឱកាសនិយម(Pre-ART) ក្នុងមួយខែៗ មានចំនួន ១,១៥0នាក់ និងអ្នកដែលបានចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (ART) មាន ចំនួនជាមធ្យម ៨0៨ នាក់ក្នុងមួយខែៗ នៅក្នុងត្រីមាសទី ៣នេះ ។ ល្បឿននៃការបង្កើនការព្យាបាលដោយឱសថប្រឆាំង មេរោគអេដស៍ (ART) មានក៏រឹតថយចុះបន្តិចម្តងៗ ចាប់តាំងដើមឆ្នាំ ២00៦ មក ។




***រូបទី ៨:*** *និន្នាការចំនួនអ្នកជំងឺថ្មីដែលកំពុងព្យាបាលជំងឺឱកាសនិយម(OI) និងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (ART) ពីត្រីមាសទី១ ឆ្នាំ ២០០៥ ដល់ ត្រីមាសទី៣ ឆ្នាំ ២០០៦*

ចំនួនសរុបនៃអ្នកជំងឺឱកាសនិយមពេញវ័យទាំងអស់មាន ៨,០៤៣នាក់ ដែលមិនទាន់សមស្របទទួលការព្យាបាលដោយឱសថ ប្រឆាំងមេរោគអេដស៍ (ART) នៅចុងត្រីមាសទី ៣ ឆ្នាំ២០០៦ ។ ក្នុងនោះមាន ៥,២៨៨នាក់(៦៥.៨%) ជាស្ត្រី, រូបភាពនេះ បង្ហាញថា ស្ត្រីភាគច្រើនដែលបានមកព្យាបាលនេះ ជាដៃគូរបស់អ្នកជំងឺបុរស ដែលបានទទួលឱសថប្រឆាំងមេរោគអេដស៍ (ART) កាលពីប៉ុន្មានឆ្នាំកន្លងទៅ ។

ក្នុងចំណោមប្រជាជនទាំងអស់, មានអ្នកជំងឺពេញវ័យ ២,៤២៤នាក់ និងកុមារ ១៧៨នាក់ ដែលបានចុះបញ្ជីទទួលការព្យាបាល -ថែទាំជំងឺឱកាសនិយម(OI) សមស្របទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (ART) ប៉ុន្តែពុំទាន់បានទទួល ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍(ART) នៅចុងត្រីមាសទី ៣ ឆ្នាំ ២០០៦ ។ មាន ២ ឬ ៣មណ្ឌល មានអ្នក ជំងឺជាច្រើននាក់ដែលរង់ចាំទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍(ART) និងមានការលំបាកក្នុងការទទួល ។

### ***ការចល័តអ្នកជំងឺតាមសេវាផ្សេងៗ***

ក្នុងត្រីមាសទី ៣ ២០០៦, ចំនួន ២២៨នាក់ នៃអ្នកជំងឺ ART ត្រូវបានបញ្ជូនចេញទៅកាន់មណ្ឌល ART ថ្មី ដែលស្ថិតនៅជិតផ្ទះ ឬកន្លែងរស់នៅរបស់ពួកគេ (មន្ទីរពេទ្យបង្អែកខេត្តសៀមរាប និងមន្ទីរពេទ្យបង្អែកតាកែវ នៅតែមានតួលេខអ្នកជំងឺដែលបញ្ជូនចេញនៅឡើយ) ។ ***មានអ្នកជំងឺជា កុមារសរុបចំនួន ៦៦នាក់ ត្រូវបានបញ្ជូនចេញ ដោយអង្គការម៉ារីណុល ទៅកាន់ អង្គការ NGO ផ្សេងៗទៀត ។***

### ២.២.៣- សេវាការពារការចំលងមេរោគអេដស៍ពីម្ដាយទៅកូន (PMTCT)

ចាប់ពីខែ មករា ដល់ កញ្ញា ឆ្នាំ ២០០៦ ស្ត្រីមានផ្ទៃពោះចំនួន ៣១,៩៥៦នាក់ បានមកធ្វើការពិនិត្យផ្ទៃពោះលើកដំបូង នៅ គ្លីនិកពិនិត្យផ្ទៃពោះមុនពេលសំរាល ដែលមានសេវាការពារការចំលងមេរោគអេដស៍ពីម្ដាយទៅកូន (PMTCT) ក្នុងនោះ ២១,៣១៧នាក់ (៦៦,៦%) បានធ្វើតេស្តរកមេរោគអេដស៍ (**ឧបសម្ព័ន្ធ:PMTCT អាំងឌីកាទ័រ៣**) ។ ក្នុងចំណោមស្ត្រីដែលបាន មកធ្វើការពិនិត្យផ្ទៃពោះលើកដំបូងនៅសេវា PMTCT មានចំនួន ១៩,៤២១នាក់ (៦០,៧%) បានទទួលលទ្ធផលតេស្តឈាម និងទទួលការផ្ដល់ប្រឹក្សាក្រោយពេលធ្វើតេស្ត (**ឧបសម្ព័ន្ធ: PMTCT អាំងឌីកាទ័រ៤**) ។ ក្នុងចំណោមប្ដីប្រពន្ធទាំងអស់ ក្នុងនោះ មានស្ត្រីបានមកពិនិត្យនៅគ្លីនិកពិនិត្យផ្ទៃពោះមុនពេលសំរាល ដែលមានសេវាការពារការចំលងមេរោគអេដស៍ពីម្ដាយទៅកូន (PMTCT) សំរាប់ការមកពិនិត្យលើកដំបូងរបស់ពួកគេ, ក្នុងនោះប្ដី/ដៃគូចំនួន ៥,០០១នាក់ (១៥.៦%) ក៏បានទទួលការ ផ្ដល់ប្រឹក្សាក្រោយពេលធ្វើតេស្ត (**ឧបសម្ព័ន្ធ: PMTCT អាំងឌីកាទ័រ៥**) ។ ក្នុងចំណោមស្ត្រីដែលបានមកធ្វើតេស្តឈាមរកមេរោគ អេដស៍ នៅសេវា PMTCT ចំនួន ៣១៩នាក់ (១.៥%) មានលទ្ធផលវិជ្ជមាន ។ ជាបន្ថែម ចាប់តាំងពីខែ មករា ដល់ កញ្ញា ឆ្នាំ ២០០៦នេះ ស្ត្រីមានផ្ទៃពោះ ចំនួន ១៥៦នាក់ ត្រូវបានដឹងថា មានផ្ទុកមេរោគអេដស៍ ដែលត្រូវបានបញ្ជូនពីក្រុមថែទាំបន្ត (CoC) ទៅសេវា PMTCT ។ ស្ត្រីមានផ្ទៃពោះចំនួន ២៣៨នាក់ ដែលមានផ្ទុកមេរោគអេដស៍ បានមកពិនិត្យតាមដានបន្តនៅ សេវា PMTCT ត្រូវបានទទួលក្នុងរយៈពេលចាប់ពីខែ មករា ដល់ កញ្ញា ឆ្នាំ ២០០៦ ។ ក្នុងនោះមាន ៦៥នាក់ (២៧.៣%) សមស្របទទួល ART និងចាប់ផ្ដើម HAART នេះគឺដូចគ្នា និងតួលេខដែលបានបង្ហាញខាងលើ ។ ទារកចំនួន ២៣៨នាក់ នៃម្ដាយដែលមានផ្ទុកមេរោគអេដស៍ ត្រូវបានរកឃើញនៅសេវា PMTCT ដែលបានសំរាលក្នុងចន្លោះពីខែ មករា ដល់ កញ្ញា ឆ្នាំ ២០០៦, ២២៧នាក់(៩៥.៤%) បានទទួលឱសថបង្ការ ARV, ក្នុងនោះ ១២៧នាក់ (៥៦.០%) ទទួល Single dose NPV តែប៉ុណ្ណោះ និង ១០០នាក់ (៤៤.០%) ទទួល NPV និង ZDV (**ឧបសម្ព័ន្ធ:PMTCT អាំងឌីកាទ័រ៦**) (**រូបទី១០**) ។ សមាមាត្រនៃក្មេងដែលកំពុងទទួល NPV និង ZDV មានការកើនឡើងយ៉ាងខ្លាំងនៅក្នុងត្រីមាសទី ៣ ឆ្នាំ ២០០៦ ដូចជា អនុសាសន៍ក្នុងគោលការណ៍ណែនាំរបស់ PMTCT ( PMTCT guidelines ) ។ ចំពោះកុមារ ដែលកើតមក ហើយបានឆ្លង មេរោគអេដស៍ពីម្ដាយ ដែលបានទទួលឱសថបង្ការ ARV នៅពេលកើត គឺ មានតែម្នាក់ ប៉ុណ្ណោះ ដែលបានរកឃើញមាន មេរោគអេដស៍ នៅអាយុ ១៨ ខែ ។




***រូបទី ៩ :*** *PMTCT cascade នៅគ្លីនិកពិនិត្យផ្ទៃពោះមុនពេលសំរាល (ANC) ដែលមានសេវាPMTCT ពីខែមករា ដល់ខែ កញ្ញា ឆ្នាំ ២០០៦*

## ២.២.៤- ការសហកាត្មារវាង TB/HIV

បច្ចុប្បន្ននេះ , មានមណ្ឌលសុខភាពចំនួន ១៨២កន្លែង ត្រូវបានជ្រើសរើសនៅស្រុកប្រតិបត្តិចំនួន ១២ ក្នុងបណ្តាខេត្ត-ក្រុង ចំនួន ៧ មានៈ ខេត្តស្វាយរៀង (៣៧ HC/៣៧), ខេត្តព្រៃវែង (២៤ HC/៩០), ខេត្តតាកែវ (៤០ HC/៧០), ខេត្តកំពត (១៥ HC/៤៧), ក្រុងព្រះសីហនុ (១០ HC/១១), ខេត្តកណ្តាល (៤០ HC/៨៨)និងខេត្តសៀមរាប (១៦ HC/៩៣) ដើម្បីធ្វើអោយប្រសើរឡើងនូវសកម្មភាពរួមសហការ TB/HIV ។ ជាពិសេសមណ្ឌលសុខភាពជាមួយនិងក្រុមថែទាំតាមផ្ទះ HBC បានជួយសំរួលដល់ការដឹកជញ្ជូនអ្នកជំងឺរបេង ពីសហគមន៏ទៅកាន់សេវា VCCT ដែលស្ថិតនៅជិតបំផុត ដើម្បីធ្វើ តេស្ត ឈាមរកមេរោគអេដស៏ ។

ចំពោះមណ្ឌលសុខភាពទាំង ១៨២កន្លែង, នៅក្នុងត្រីមាសទី ៣ ឆ្នាំ ២០០៦ បានរកឃើញអ្នកជំងឺរបេងករណីថ្មី ចំនួន ៤,៤០១នាក់ នឹង របេងករណីចាស់ ដែលកំពុងព្យាបាល ប៉ុន្តែមិនទាន់បានធ្វើតេស្តឈាមរកមេរោគអេដស៏នៅឡើយ ។ អ្នកជំងឺ ចំនួន ១,៤៩៣នាក់ (៣៣,៩%) ត្រូវបានរាយការណ៏ដោយក្រុមថែទាំតាមផ្ទះ HBC ដែលកំពុងរង់ចាំទៅកាន់មណ្ឌលផ្តល់សេវា VCCT ដើម្បីធ្វើតេស្តឈាមរកមេរោគអេដស៏ (តារាងទី៤) ។ សមាមាត្រនៃអ្នកជំងឺរបេង ដែលបានរកឃើញមានមេរោគអេដស៏វិជ្ជមាន មានភាពខុសប្លែកគ្នាពី ១០,០% ទៅ ២៥,៣% ដោយយកខេត្តជាគោលលើកលែង ខេត្តស្វាយរៀង ដែលរកឃើញមានតែ ២,០% នៃអ្នកជំងឺរបេង ដែលបានធ្វើតេស្តឈាមរកមេរោគអេដស៏ ហើយទទួលលទ្ធផលវិជ្ជមាន ។ អ្នកជំងឺដែលមានជំងឺរបេង/អេដស៏ ត្រូវបានបញ្ជូនទៅកាន់សេវា OI/ART ។

ចាប់តាំងពីខែ មករា ឆ្នាំ ២០០៦ ចំនួនអ្នកជំងឺរបេងសរុបមាន ២,៩២៨នាក់ ត្រូវបានដឹកជញ្ជូនដោយក្រុមថែទាំតាមផ្ទះពីសហគមន៍របស់ពួកគេទៅកាន់មណ្ឌល VCCT ដើម្បីធ្វើតេស្តឈាមរកមេរោគអេដស៍( **ឧបសម្ព័ន្ធ: HBC អាំងឌីកាទ័រ ៣**) ។ ទិសដៅក្នុងឆ្នាំ ២០០៦ អ្នកជំងឺរបេងចំនួន ៥,០០០នាក់ ត្រូវបានបញ្ជូនទៅសេវា VCCT ដោយក្រុមថែទាំតាមផ្ទះ ការដាក់ផែនការសំរាប់ខេត្តទាំង ៧ ប្រហែលជាមានការលំបាកក្នុងការសំរេចគោលដៅ ប៉ុន្តែសមាមាត្រនៃអ្នកជំងឺរបេង ដែលបានបញ្ជូនទៅកាន់មណ្ឌល VCCT ដោយក្រុមថែទាំតាមផ្ទះមានការកើនឡើងចាប់តាំងពីខែ មករា ឆ្នាំ ២០០៦ មក ( រូបទី១១) ។

| | ៧ ខេត្ត-ក្រុង **N*=4,401** ភាគរយ (%) | កំពត **N =201** ភាគរយ(%) | កណ្តាល **N =778** ភាគរយ(%) | ព្រៃវែង **N =961** ភាគរយ(%) | សៀមរាប **N =320** ភាគរយ(%) | ក្រុងព្រះសីហនុ **N =234** ភាគរយ (%) | ស្វាយរៀង **N =1.768** ភាគរយ(%) | តាកែវ **N =139** ភាគរយ(%) |
|---|---|---|---|---|---|---|---|---|
| របាយការណ៍របស់ក្រុមថែទាំតាមផ្ទះដែរបានធ្វើតេស្តរកមេរោគអេដស៍នៅ VCCT | 1.493 (33.9) | 82 (40.8) | 158 (20.3) | 522(54.3) | 81 (25.3) | 12 (5.1) | 607 (34.3) | 31 (22.3) |
| របាយការណ៍បញ្ជូនរបស់ក្រុម HBC ដែរមានរោគអេដស៍វិជ្ជមាន | 176 (11.8) | 18 (22.0) | 40 (25.3) | 52(10.0) | 12 (14.8) | 2 (16.7) | 12 (2.0) | 40§ |

***តារាងទី ៤:*** *ការបញ្ជូនអ្នកជំងឺរបេងថ្មី ទៅសេវាVCCT ដើម្បីធ្វើតេស្តឈាមរកមេរោគអេដស៍តាមបណ្តាខេត្ត-ក្រុងចំនួន៧ និង ១៨២មណ្ឌលសុខភាព ជាសកម្មភាពសហការរវាងកម្មវិធីរបេង/អេដស៍ ក្នុងត្រីមាសទី ៣ ឆ្នាំ ២០០៦ ( របាយការពីក្រុម HBC )*

N*=ចំនួននៃអ្នកជំងឺរបេងថ្មី នៅក្នុងត្រីមាសទី៣ + ចំនួននៃអ្នកជំងឺរបេងចាស់ ដែលកំពុងព្យាបាល ប៉ុន្តែមិនទាន់ធ្វើតេស្តឈាមរកមេរោគ អេដស៍នៅទាំង ១៨២ មណ្ឌលសុខភាព ។

§ នៅខែត្តតាកែវ, សមាមាត្រខ្ពស់នៃអ្នកជំងឺរបេង ដែលបានទៅកាន់មណ្ឌល VCCT ដោយខ្លួនឯង ដោយពុំមានក្រុម HBC ដឹកនាំទៅទេ ពីមុនមក ។




***រូបទី១០:*** *និន្នាការចំនួនអ្នកជំងឺរបេង ដែរបានបញ្ជូនដោយក្រុមថែទាំតាមផ្ទះពីទាំង៧ ខេត្ត/ក្រុង ដែលបានទៅធ្វើតេស្តឈាម រកមេរោគអេដស៍ នៅមណ្ឌល VCCT  ក្នុង ឆ្នាំ ២០០៦*

ក្នុងចំណោមមណ្ឌលសុខភាព ដែលមានក្រុមថែទាំតាមផ្ទះ HBC ទាំង ៧ ខេត្ត/ក្រុង ពុំមែនសុទ្ធតែមានសកម្មភាព សហការគ្នា រវាងរបេងអេដស៍ទាំងអស់នោះទេ។ សមាមាត្រនៃអ្នកជំងឺរបេងថ្មី ដែលបានបញ្ជូនដោយក្រុមថែទាំតាមផ្ទះ ទៅកាន់ មណ្ឌល VCCT មានភាពល្អប្រសើបំផុត នៅខេត្ត ព្រៃវែង។

## ៣- វគ្គបណ្តុះបណ្តាល

### ៣.១- សេវា VCCT

ក្នុងត្រីមាសទី ៣ ឆ្នាំ ២០០៦, អ្នកផ្តល់ប្រឹក្សាចំនួន ២៦នាក់ និងអ្នកបច្ចេកទេសមន្ទីរពិសោធន៍ចំនួន ២៦នាក់ ត្រូវបាន បណ្តុះ បណ្តាល។

### ៣.២- សេវា OI/ART

វគ្គបណ្តុះបណ្តាលដំបូង សំរាប់ក្រុម OI/ART ដោយរាប់បញ្ចូល ៥ខែដំបូង ក្នុងវគ្គផ្តល់សេវាសំរាប់គ្រូពេទ្យពិនិត្យ ជំងឺផ្ទាល់, និង វគ្គ ៣សប្តាហ៍ សំរាប់គ្រូពេទ្យផ្តល់ប្រឹក្សា, វគ្គ ៣សប្តាហ៍ សំរាប់ឱសថការី នឹងមន្ត្រីគ្រប់គ្រងឱសថ និង បរិក្ខារ នឹងវគ្គខ្លីៗ សំរាប់បុគ្គលិកជំនួយ។ ក្រុម OI/ART ក៏ទទួលផងដែរនូវវគ្គបណ្តុះបណ្តាល " លើកទីពីរ " ដើម្បី បង្កើនសមត្ថភាពបន្ថែមលើ ការពិនិត្យព្យាបាល ដែលមានកន្លងមក មុនពេលមានការងារនេះ សំរាប់ទៅបង្កើតមណ្ឌល

OI/ART ថ្មី។ ក្នុងត្រីមាសទី ៣ ឆ្នាំ ២០០៦ អ្នកពិនិត្យព្យាបាលមានចំនួន ២៩នាក់, គ្រូពេទ្យអ្នកផ្តល់ប្រឹក្សា ២៩នាក់ និង ឱសថការី ២១នាក់ ទទួលបានការបណ្តុះ បណ្តាល។ ចាប់តាំងពីឆ្នាំ ២០០៤ មក គ្រូពេទ្យពិនិត្យព្យាបាល ១៤៦នាក់ ត្រូវបានបណ្តុះបណ្តាលរួចរាល់( **ឧបសម្ព័ន្ធ: HFBC អាំងឌីការទ័ ៤**)។

## ៤- ការគាំទ្រផ្នែកឱសថ នឹង សម្ភារៈបរិក្ខារ

បច្ចុប្បន្នពុំមានមណ្ឌល OI/ART ណាមួយ ដាច់ស្តុកសន្និធិនៃឱសថចាំបាច់ ART ទេ ( **ឧបសម្ព័ន្ធ: HFBC អាំងឌីការទ័ ៥**) ។ ក្នុងត្រីមាសទី ៣ ឆ្នាំ ២០០៦នេះ មណ្ឌល ART ទាំងអស់ បានធ្វើរបាយការណ៍ចំនួនអ្នកជំងឺតាមរូបមន្តឱសថ ART នីមួយៗ។

វេជ្ជបញ្ជាប្រើប្រាស់រូបមន្តឱសថភាគច្រើន គឺ d4t+3TC+NVP, d4t+3TC+EFV នឹង AZT+3TC+NVP ដោយមាន ១.៨% នៃមនុស្សពេញវ័យ និង ១.៤%នៃកុមារ ត្រូវបានទទួលរូបមន្តឱសថ PI-Based (តារាង ទី៦) ។ សមាមាត្រនៃអ្នកជំងឺជាមនុស្សពេញវ័យដែលបានទទួលរូបមន្តឱសថ PI-Based មានការកើនឡើងគួរអោយកត់សំគាល់ ចាប់តាំងពីត្រីមាសកន្លងទៅ។ មណ្ឌល OI/ART បានធ្វើសំណើដើម្បីរាយការណ៍នូវរូបមន្តប្រើប្រាស់ឱសថ ART ទៅតាមវេជ្ជបញ្ជាអោយបាន ត្រឹមត្រូវទៅនឹងការផ្គត់ផ្គង់។

| រូបមន្តនៃការប្រើប្រាស់ឱសថ ARV | មនុស្សពេញវ័យ<br>N= 16,586*<br>No. (%) | កុមារ<br>N= 1,610*<br>No. (%) |
|---|---|---|
| d4t+3TC+NVP | 8,332 (50.2) | 1,199 (74.5) |
| d4t+3TC+EFV | 2,734 (16.5) | 321(19.9) |
| AZT+3TC+NVP | 3,528 (21.3) | 32 (2.0) |
| AZT+3TC+EFV | 1,160 (7.0) | 29 (1.8) |
| PI-based regimens | 298 (1.8) | 22 (1.4) |
| Other regimens | 534 (3.2) | 7 (0.4) |

*ទិន្នន័យរូបមន្តនៃការប្រើប្រាស់ឱសថ មិនបានត្រឹមត្រូវពិតប្រាកដជាក់ស្តែងទៅ នឹងចំនួនតួរលេខរបស់អ្នកជំងឺ ART ទេ ។

***តារាងទី ៦*** *: វេជ្ជបញ្ជាស្តីពីការប្រើប្រាស់ នឹងការចែកចាយរូបមន្តឱសថប្រឆាំងមេរោគសំរាប់អ្នកផ្ទុកមេរោគ HIV នៅកម្ពុជា ថ្ងៃទី៣០ ខែ កញ្ញា ឆ្នាំ ២០០៦*

## ឧបសម្ព័ន៖ ការត្រួតពិនិត្យ និងការវាយតំលៃទិសដៅ

| | STI អាំងឌីកាទ័រ (NCHADS) | ទិសដៅឆ្នាំ ២០០៦ N (%) | អត្រានៅត្រីមាសទី៣ ឆ្នាំ ២០០៦ |
|---|---|---|---|
| ១ | ចំនួន និងភាគរយ គ្លីនិកដែលជំនាញ STI ដែលមានមន្ទីរពិសោធសំរាប់ RPR តេស្តនិង microscopy basic | ៣០% | ២៩ (៩៦,៧%) ,១៦កំពុងដំណើរការ, ១៣ បានបំពាក់រួចរាល់ តែពុំទាន់ដំណើរការ |
| ២ | សមាមាត្រនៃរោគវិនិច្ឆ័យជំងឺរលាកស្បូនចំពោះស្ត្រីរកស៊ីផ្លូវភេទដោយផ្ទាល់ក្នុងពេលមកតាមដាន និងប្រឹក្សានៅគ្លីនិកជំនាញ STI | < ២៥% | ១៧,៨% |
| ៣ | អត្រាប្រេវ៉ាឡង់ STI ក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទដោយផ្ទាល់ ( N Gonorrhea និង/ឬ Chlamydiae trachomatis ) | < ២៥% | ១៣,០% សំរាប់ NG ១៤,០% សំរាប់ CT |

| | អាំងឌីកាទ័រ ក្រុមថែទាំបន្ត CoC (NCHADS) | ទិសដៅក្នុងឆ្នាំ ២០០៦, N (%) | អត្រានៅត្រីមាសទី២ ឆ្នាំ ២០០៦, N (%) |
|---|---|---|---|
| ១ | ចំនួនស្រុកប្រតិបត្តិសរុប និង ក្រុម CoC | ៣០ | ២៨ |

| | VCCT អាំងឌីកាទ័រ (NCHADS) | ទិសដៅក្នុងឆ្នាំ ២០០៦, N (%) | អត្រានៅត្រីមាសទី២ ឆ្នាំ ២០០៦, N (%) |
|---|---|---|---|
| ១ | ចំនួន និងមណ្ឌល VCCT ដែលអនុញ្ញាតអោយបំរើការជាសាធារណៈ នឹងមិនយកកំរៃ | ១២៥ | ១២៤ |
| ២ | ចំនួននិងអាត្រាភាគរយនៃមនុស្សពេញវ័យ( អាយុពី១៥-៤៩) ជាអ្នកដែលបានទទួលការផ្តល់ប្រឹក្សានឹងធ្វើតេស្តរកមេរោគ HIV++ | ១៦៩,០០០(២,៦%) នៅចុងឆ្នាំ | ១៣៨,០៥៣ ពីខែ មករា ដល់ កញ្ញា |
| ៣ | អាត្រាភាគរយនៃការធ្វើតេស្តអ្នកដែលទទួលលទ្ធផលតាមរយការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្ត | ៩៨% | ៩៨,៦% |
| ៤ | ចំនួនភាគរយនៃអតិថិជន VCCT ដែលត្រូវបានបញ្ជូនពីកម្មវិធីរបេង | - | ៣,៤១៤ (៦,១%) |

| | អាំងឌីកាទ័រ ការថែទាំតាមសេវាសុខាភិបាល (NCHADS) | ទិសដៅក្នុងឆ្នាំ ២០០៦, N (%) | អត្រានៅត្រីមាស ទី៣ ឆ្នាំ ២០០៦, N (%) |
|---|---|---|---|
| ១ | ចំនួន(%) នៃ OD[1] ដែលមានមណ្ឌលផ្តល់សេវា ART យ៉ាងតិចមួយកន្លែង | ៣០ | ៣០ រួមទាំង ក្រុងភ្នំពេញ ចំនួន៤ OD |
| ២ | ចំនួន(%) នៃ OD ដែលមានមណ្ឌលផ្តល់សេវា PMTCT យ៉ាងតិចមួយកន្លែង | ២៣ | ៣៤ |
| ៣ | ចំនួន(%) ករណីមេរោគអេដស៍នៃ HAART | ១៦,០០០ | ១៦,៦៨៥ ជាមនុស្សពេញវ័យ,ដោយរាប់បញ្ចូលទាំង ៨,៤១៩(៥០,៥%) ជាស្ត្រី និង +១,៥៧១ ជាកុមារ<br>១៨,២៥៦ សរុប |
| ៤ | ចំនួនគ្រូពេទ្យដែលបានបណ្តុះបណ្តាលក្នុងការផ្តល់ឱសថ ARVs | ៧៥ | ១៤៦ |
| ៥ | ចំនួន(%) នៃមណ្ឌល OI/ART ដែលអស់ស្តុកនៃឱសថ ART | 0% | 0% |
| ៦ | ភាគរយនៃចំនួនអ្នកផ្ទុកមេរោគអេដស៍ហើយនៅរស់នៅឡើយរយៈពេល១២ ខែ បន្ទាប់ពីពេលកមពិនិត្យលើកដំបូង | > ៨0% | > ៨0% |

| | ***អាំងឌីកាទ័ សេវាការថែទាំសុខភាពតាមផ្ទះ*** (NCHADS) | ទិសដៅក្នុងឆ្នាំ ២០០៦ | អត្រានៅត្រីមាស ទី៣ ឆ្នាំ ២០០៦ |
|---|---|---|---|
| ១ | ចំនួនសរុប នៃក្រុមផ្តល់សេវាថែទាំសុខភាពតាមផ្ទះ នឹងសេវាគាំទ្រអ្នកផ្ទុកមេរោគអេដស៍ | ២៧០ | ២៩២ |
| ២ | ចំនួនអ្នកផ្ទុកមេរោគអេដស៍ ដែលបានគាំទ្រដោយក្រុមផ្តល់សេវាថែទាំសុខភាពតាមផ្ទះ | ១៦,០០០ | ១៨,៨៩៩ |
| ៣ | ចំនួនអ្នកជំងឺរបេង ដែលបញ្ជូនដោយក្រុមថែទាំសុខភាពតាមផ្ទះទៅសេវា **VCCT** | ៥០០០ | ៣១៤ត្រីមាសទី១-០៦<br>៧២១ត្រីមាសទី២-០៦<br>១,៤៩៣ត្រីមាសទី៣-០៦<br>២,៥២៨ |
| ៤ | ចំនួន (ភាគរយ) នៃមណ្ឌលសុខភាព ដែលមានក្រុមថែទាំសុខភាពតាមផ្ទះ | ៣៥%នៃ៩៤២ HC | ៤៩៣(៥២,៣%) |

[1] ប្រទេសកម្ពុជាមាន ២៤ខេត្ត-ក្រុង, ៧៦ ស្រុកប្រតិបត្តិ **(OD)** ដោយរាប់បញ្ចូលទាំង ស្រុកប្រតិបត្តិចំនួន ៦៨ ដែលមានមន្ទីរពេទ្យបង្អែក

| | អាំងឌីកាទ័ ការបង្ការការឆ្លងមេរោគអេដស៍ពីម្តាយទៅកូន PMTCT (NCHADS) | ទិសដៅក្នុងឆ្នាំ ២០០៦ No.(%) | អត្រានៅត្រីមាសទី១-៣ ឆ្នាំ ២០០៦ No.(%) |
|---|---|---|---|
| ១ | ចំនួនមណ្ឌល PMTCT | ៣៥ | ៥៤ រួមទាំង ៣១ មន្ទីរពេទ្យបង្អែក RH |
| ២ | ចំនួន ( % ) ODs ដែលយ៉ាងតិចមានមណ្ឌលមួយដោយយោលទៅតាម minimum package នៃសេវា PMTCT | ២៣ | ៣៤ |
| ៣ | ភាគរយ (%) ស្ត្រីមកពិនិត្យផ្ទៃពោះមុនពេលសំរាល ANC 1 ដែលបានទទួលការធ្វើតេស្តឈាមរកមេរោគអេដស៍នៅមណ្ឌល PMTCT | | ២១,៣១៧ (៦៦,៦%) |
| ៤ | ភាគរយ (%) ស្ត្រីមកពិនិត្យផ្ទៃពោះមុនពេលសំរាល ANC 1 ស្ត្រីដែលបានទទួលការប្រឹក្សានៅក្រោយពេលធ្វើតេស្ត | | ១៩,៤២១ (៦០,៧%) |
| ៥ | ភាគរយនៃស្វាមី ឬ ដៃគូដែលបានទទួលការប្រឹក្សានៅក្រោយពេលធ្វើតេស្ត តាមរយៈកម្មវិធី PMTCT | | ៥,០០១ (១៥,៦%) |
| ៦ | ចំនួន ( % ) ទារកដែលកើតមកឆ្លងមេរោគអេដស៍ពីម្តាយដែលការកំណត់អត្តសញ្ញាណ គឺតាមរយៈកម្មវិធី PMTCTដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលស្តីអំពីការបង្ការដោយប្រើប្រាស់ឱសថ ARV | | ២២៧ (៩៥,៤%) រួមបញ្ចូល១២៧(៥៦,០%)SD NPV នឹង១០០ (៤៤,០%) NPV+ZDV |
| ៧ | ចំនួន ( % ) ទារកដែលកើតមកឆ្លងមេរោគអេដស៍ពីម្តាយ ហើយបានទទួលឱសថបង្ការ ARV នៅពេលកើត នឹងបានឆ្លងមេរោគ HIV នៅពេលមានអាយុ ១៨ ខែ | | ១ |

## ៣. របាយការណ៍ថវិកា

នៅក្នុងគំរោងផែនការប្រចាំឆ្នាំ ២០០៦នេះ រួមបញ្ចូលទាំងថវិកាសំរាប់លើកទឹកចិត្តផង មានសរុប ទាំងអស់ ៨,៦៩៦,៥៦២ ដុល្លា ដែលក្នុងនោះ មាន ៧%ភាគរយសំរាប់កម្មវិធីបង្ការ និង ៤៧% សំរាប់ការ ព្យាបាល និងថែទាំបន្តដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ (រួមទាំងឱសថប្រឆាំងមេរោគអេដស៍) ១៤% សំរាប់ការអង្កេតស្រាវជ្រាវ និង ការគ្រប់គ្រងទិន្នន័យ និង ៣២% សំរាប់ការងារផែនការតាមដាន និងរដ្ឋបាល ។ ហើយក្នុងនោះ មានថវិកាប្រហែល ៦០%ដែលគ្រប់គ្រងដោយមជ្ឈមណ្ឌលជាតិផ្ទាល់ និង ៤០%ទៀត ជាថវិកា របស់ដៃគូការងារក្នុងការប្រយុទ្ធទប់ស្កាត់នឹង ជំងឺអេដស៍ ។

របាយការណ៍នេះ បង្ហាញពីការចំណាយ ធៀបទៅនឹងគំរោងផែនការ ត្រីមាសទី៣ ឆ្នាំ ២០០៦ ដែលជាអាំងឌីកាទ័រសំខាន់សំរាប់សមិទ្ធិផលដែលសំរេចបានក្នុងត្រីមាសនេះ ។របាយការណ៏នេះ រួមបញ្ចូលទាំងប្រភពសំខាន់ៗទាំង៦ នៃការផ្តល់ជាមូលនិធិសំរាប់ទ្រទ្រង់កម្មវិធី របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ ដូចជា DFID, GFATM, CDC, EUROPAID, CHAI, CTAP, និង របាយការណ៏ថវិកា FHI ដែលបានមកពីអង្គការ FHI ។

នៅក្នុងតារាងនៃការចំណាយដែលបានលើកយកមកនេះ មានតែការចំណាយដែលមាននៅក្នុងប្រព័ន្ធគណនេយ្យ របស់មជ្ឈមណ្ឌលជាតិប៉ុណ្ណោះ។ ទាំងនេះរួមបញ្ចូលទាំងការចំណាយជាក់ស្តែងដែលត្រូវបានចាយនិងបានកត់ត្រាក្នុងកំឡុង ពេលនៃត្រីមាសនេះ ។

នៅក្នុងត្រីមាសទី៣ ឆ្នាំ ២០០៦ នេះ ថវិកាចំនួន ១,៤៣៧,២៦៧ ដុល្លាអាមេរិក ត្រូវបានចំណាយ គឺប្រហែល ៧៨% បើធៀបទៅនឹងគំរោងផែនការត្រីមាសទី៣ និង ៤៥% បើធៀបទៅគំរោង ថវិកាប្រចាំឆ្នាំ ដែលគ្រប់គ្រងដោយមជ្ឈមណ្ឌលជាតិ ។

- គំរោង **DFID** ចំណាយបាន ៧០% នៃគំរោងផែនការ
- គំរោង **EUROPAID** ចំណាយបាន ៧៨% នៃគំរោងផែនការ
- គំរោង **GFATM** ចំណាយបាន ១០២% នៃគំរោងផែនការ
- គំរោង **CDC** ចំណាយបាន ៨២ % នៃគំរោងផែនការ
- គំរោង **CTAP** ចំណាយបាន ៥២% នៃគំរោងផែនការ
- គំរោង **CHAI** ចំណាយបាន ៤២% នៃគំរោងផែនការ
- គំរោង **FHI** ចំណាយបាន ៦៣% នៃគំរោងផែនការ

**តារាងទី១: សង្ខេបថវិកាដែលបានចំណាយ នៅតាមប្រភពថវិកា**

| ប្រភពថវិកា | ផែនការប្រចាំឆ្នាំ | ផែនការប្រចាំត្រីមាសទី២ | ចំណាយត្រីមាសទី២ | Q2 % | A % |
|---|---|---|---|---|---|
| DFID | $ 1,909,878 | $ 545,107 | $ 379,424 | 70% | 53% |
| GFATM | $ 2,608,922 | $ 526,408 | $ 536,457 | 102% | 42% |
| EUROPAID | $ 592,302 | $ 273,512 | $ 212,549 | 78% | 46% |
| CDC | $ 786,158 | $ 197,851 | $ 161,666 | 82% | 47% |
| CHAI | $ 221,600 | $ 95,950 | $ 40,621 | 42% | 28% |
| FHI | $ 122,484 | $16,552 | $ 10,362 | 63% | 39% |

| | | | | | |
|---|---|---|---|---|---|
| UNSW/ CTAP | $ 744,377 | $ 186,094 | $ 96,188 | 52% | 39% |
| **សរុប** | **$ 6,915,386** | **$ 1,841,474** | **$1,437,267** | **78%** | **45%** |

ការចំណាយថវិកានេះ ភាគច្រើននៅថ្នាក់ខេត្ត មានភាពខ្ពស់ជាងនៅថ្នាក់ជាតិ :

- ខេត្តដែលប្រើប្រាស់ថវិកានៅក្រោមគំរោង DFID ចំណាយបាន៧៩%នៃគំរោងផែនការ, ចំណែកឯមជ្ឈមណ្ឌលជាតិចំណាយបាន៦៨%
- ខេត្តដែលប្រើប្រាស់ថវិកានៅក្រោមគំរោង CDC ចំណាយបាន ១៣១%នៃផែនការ, ចំណែក មជ្ឈមណ្ឌលជាតិចំណាយបានតែ ៧១% ប៉ុណ្ណោះ ព្រោះការចំណាយភាគច្រើនយឺតដោយសារការ ធ្វើលទ្ធកម្ម។
- ស្រុកប្រតិបត្តិចំនួន៣ នៃខេត្ត២ (តាកែវ និងពោធិសាត់) ដែលប្រើប្រាស់ថវិកាអស់ ៧៩% និងថ្នាក់ជាតិ អស់៧៧%នៃផែនការ
- ចំពោះគំរោង CTAP ការចំណាយសំរាប់ដំណើរតែការងារថែទាំ និងព្យាបាលដល់អ្នកជំងឺអេដស៍ នៅគ្លីនិកសុខភាព សង្គម និងមូលនិធិគ្លីនតុន (CHAI) ចំណាយតែនៅថ្នាក់ជាតិប៉ុណ្ណោះ.
- ខេត្ត ៩ ដែលប្រើប្រាស់ថវិកានៅក្រោមគំរោង GFATM-R2 (បាត់ដំបង, កំពង់ឆ្នាំង, កំពង់ធំ, កំពង់ស្ពឺ, កណ្តាល, កំពត, ព្រៃវែង, សៀមរាប, ស្វាយរៀង ) ចំណាយបាន ៨៨%នៃផែនការ, ហើយខេត្ត ៦ ដែលប្រើប្រាស់ថវិកា នៅក្រោមគំរោង GFATM-R1 (កំពង់ចាម, ពោធិសាត់, ប៉ៃលិន, ក្រុងព្រះសីហនុ, ភ្នំពេញ និងតាកែវ ) ចំណាយ បាន ៤១% នៃផែនការ, មជ្ឈមណ្ឌលជាតិ ចំណាយបាន ១០៧%។

**តារាងទី២ : សង្ខេបថវិកាចំណាយរបស់មជ្ឈមណ្ឌលជាតិ**

| DFID | Annual Plan | Q3 Plan | Q3 Act | Q3 % | % |
|---|---|---|---|---|---|
| BCC Unit | $ 131,220 | 53,210 | 34,950 | 66% | 66% |
| STD Unit | $ 26,740 | 18,923 | 3,624 | 19% | 41% |
| AIDS Care Unit | $ 266,963 | 72,000 | 56,243 | 78% | 54% |
| VCCT | $ 70,681 | 24,219 | 17,890 | 74% | 32% |
| Research Unit | $ 68,000 | 19,224 | 5,350 | 28% | 43% |
| Planning & Monitoring & Admin | $ 192,482 | 64,754 | 18,428 | 28% | 41% |
| Data Management | $ 34,000 | 11,746 | 0 | 0% | 19% |
| Logistic Management | $ 224,121 | 65,421 | 52,650 | 80% | 72% |
| Admin & Finance | $ 392,660 | 130,000 | 122,503 | 94% | 64% |
| Total NCHADS | $ 1,406,867 | 459,497 | 311,638 | 68% | 56% |
| Total Provinces (23) | $ 503,011 | 85,610 | 67,786 | 79% | 44% |
| **Grand Total for DFID** | **$ 1,909,878** | **545,107** | **379,424** | **70%** | **53%** |

| EUROPAID | Annual Plan | Q3 Plan | Q3 Act | Q3 % | % |
|---|---|---|---|---|---|
| AIDS Care Unit | 1,500 | 0 | 0 | #DIV/0! | 0% |
| Planning & Monitoring & Admin | 56,160 | 23,965 | 8,185 | 34% | 59% |
| Logistic Management | 357,900 | 207,900 | 179,731 | 86% | 51% |
| Admin & Finance | 141,040 | 31,080 | 15,849 | 51% | 25% |
| Total NCHADS | 556,600 | 262,945 | 203,765 | 77% | 45% |
| Total Provinces (3ODs) | 35,702 | 10,567 | 8784 | 83% | 62% |
| **Grand Total for EUROPAID** | **592,302** | **273,512** | **212,549** | **78%** | **46%** |

| GFATM-R1, R2, R4 | Annual Plan | Q3 Plan | Q3 Act | Q3 % | % |
|---|---|---|---|---|---|
| BCC Unit | 46,200 | 21,245 | 42,855 | 202% | 93% |
| STD Unit | 22,200 | 0 | 4,389 | #DIV/0! | 124% |
| AIDS Care Unit | 343,021 | 135,474 | 64,756 | 48% | 43% |
| VCCT | 56,700 | 0 | 1,480 | #DIV/0! | 3% |
| Planning & Monitoring & Admin | 121,000 | 38,250 | 32,102 | 84% | 45% |
| Data management | 15,000 | 0 | 4,634 | #DIV/0! | 31% |
| Logistic Management | 1,342,922 | 113,075 | 252,647 | 223% | 37% |
| Admin & Finance | 434,660 | 154,140 | 90,834 | 59% | 42% |
| Total NCHADS | 2,381,703 | 462,184 | 493,697 | 107% | 40% |
| Total Provinces covered by GF-R1(6) | 125598 | 29290 | 12037 | 41% | 59% |
| Total Provinces covered by GF-R2(9) | 101621 | 34,934 | 30724 | 88% | 54% |
| **Grand Total for GFATM-R1, R2, R4** | **2,608,922** | **526,408** | **536,457** | **102%** | **42%** |

| CDC | Annual Plan | Q3 Plan | *Q3 Act* | Q3 % | % |
|---|---|---|---|---|---|
| VCCT | 14,400 | 4,990 | 4,580 | 92% | 120% |
| Surveillance Unit | 162,000 | 142,180 | 0 | 0% | 6% |
| Research Unit | 12,000 | 0 | 0 | #DIV/0! | 0% |
| Planning & Monitoring & Admin | 50,450 | 13,000 | 26,590 | 205% | 103% |
| Datamangement | 2,500 | 0 | 0 | #DIV/0! | 0% |
| Logistic Mangement | 65,565 | 0 | 50,515 | #DIV/0! | 83% |

| | | | | | |
|---|---|---|---|---|---|
| Admin & Finance | 210,300 | 2,600 | 33,954 | 1306% | 41% |
| Total NCHADS | 517,215 | 162,770 | 115,639 | 71% | 42% |
| Total Province (1) | 268943 | 35,081 | 46,027 | 131% | 55% |
| **Grand Total for CDC** | **786,158** | **197,851** | **161,666** | **82%** | **47%** |

| CHAI | Annual Plan | Q3 Plan | Q3 Act | Q3 % | % |
|---|---|---|---|---|---|
| AIDS Care Unit | 30,000 | 11,500 | 631 | 5% | 2% |
| VCCT | 10,000 | 0 | 5,285 | #DIV/0! | 72% |
| Planning & Monitoring & Admin | 80,000 | 40,000 | 12,574 | 31% | 26% |
| Logistic Management | 68,000 | 33,000 | 15,678 | 48% | 24% |
| Admin & Finance | 33,600 | 11,450 | 6,453 | 56% | 55% |
| Total NCHADS | 221,600 | 95,950 | 40,621 | 42% | 28% |
| **Grand Total for CHAI** | **221,600** | **95,950** | **40,621** | **42%** | **28%** |

| Total | Annual Plan | Q3 Plan | Q3 Act | Q3 % | % |
|---|---|---|---|---|---|
| BCC Unit | 180,420 | 77,455 | 77,805 | 100% | 72% |
| STD Unit | 67,940 | 22,475 | 11,653 | 52% | 78% |
| AIDS Care Unit | 641,484 | 218,974 | 121,630 | 56% | 46% |
| VCCT Unit | 166,781 | 29,209 | 29,235 | 100% | 34% |
| Surveillance Unit | 180,000 | 150,180 | 6,722 | 4% | 9% |
| Research Unit | 1,011,936 | 252,208 | 101,538 | 40% | 32% |
| Planning & Monitoring & Admin | 523,842 | 179,969 | 97,879 | 54% | 45% |
| Data Management | 51,500 | 11,746 | 4,634 | 39% | 21% |
| Logistic Management | 2,715,042 | 527,400 | 551,221 | 105% | 34% |
| Admin & Finance | 1,739,032 | 360,710 | 269,593 | 75% | 34% |
| Total NCHADS | 7,277,977 | 1,830,326 | 1,271,910 | 69% | 36% |
| Total Provinces | 1082359 | 195482 | 165358 | 85% | 49% |
| **Grand Total** | **8,360,336** | **2,025,808** | **1,437,267** | **71%** | **38%** |

**តារាងទី៣ : សង្ខេបថវិកាចំណាយរបស់ខេត្ត-ក្រុង**

| Province | | Total Expenditure in Q3 | | | | |
|---|---|---|---|---|---|---|
| | | DFID | GFATM | EUROPAID | CDC | Total |
| 1 | BMC | | | | $ 46,027 | $ 46,027 |
| 2 | BTB | $ 2,195 | $ 3,200 | | | $ 5,395 |
| 3 | KCM | $ 2,466 | $ 7,114 | | | $ 9,580 |
| 4 | KCN | $ 5,966 | $ 2,106 | | | $ 8,072 |
| 5 | KDL | $ 3,757 | $ 5,753 | | | $ 9,510 |
| 6 | KEP | $ 1,911 | | | | $ 1,911 |
| 7 | KPT | $ 2,837 | $ 3,451 | | | $ 6,288 |
| 8 | KTM | $ 4,548 | $ 4,208 | | | $ 8,756 |
| 9 | KRT | $ 3,382 | | | | $ 3,382 |
| 10 | KSP | $ 2,471 | $ 3,978 | | | $ 6,449 |
| 11 | KHK | $ 5,084 | | | | $ 5,084 |
| 12 | OMC | $ 3,670 | | | | $ 3,670 |
| 13 | MDK | $ 1,932 | | | | $ 1,932 |
| 14 | PLN | $ 1,675 | $ 906 | | | $ 2,581 |
| 15 | PNP | $ 787 | $ 315 | | | $ 1,102 |
| 16 | PST | $ 2,051 | $ 606 | $ 3,571 | | $ 6,228 |
| 17 | PVG | $ 5,382 | $ 3,399 | | | $ 8,781 |
| 18 | PVH | $ 2,409 | | | | $ 2,409 |
| 19 | RTK | $ 3,732 | | | | $ 3,732 |
| 20 | SRP | $ 3,310 | $ 2,279 | | | $ 5,589 |
| 21 | SHV | $ 1,489 | $ 2,466 | | | $ 3,955 |
| 22 | STG | $ 1,649 | | | | $ 1,649 |
| 23 | SVR | $ 3,046 | $ 2,350 | | | $ 5,396 |
| 24 | TKV | $ 2,037 | $ 630 | $ 5,213 | | $ 7,880 |

**តារាងទី៤ : សង្ខេបថវិកាចំណាយ របស់ខេត្ត-ក្រុង ឧបត្ថម្ភដោយ DFID**

| Provinces | | Y Plan | Q3 Plan | Q3 Act | Q3% | A % |
|---|---|---|---|---|---|---|
| 1 | BTB | $ 34,356 | $ 4,389 | $ 2,195 | 50% | 23% |
| 2 | KCM | $ 19,094 | $ 4,525 | $ 2,466 | 97% | 50% |
| 3 | KCN | $ 30,906 | $ 6,866 | $ 5,966 | 87% | 48% |
| 4 | KDL | $ 28,029 | $ 4,530 | $ 3,757 | 83% | 53% |

| | | | | | | |
|---|---|---|---|---|---|---|
| 5 | KEP | $ 16,376 | $ 2,497 | $ 1,911 | 77% | 46% |
| 6 | KPT | $ 26,480 | $ 4,923 | $ 2,837 | 58% | 54% |
| 7 | KTM | $ 33,636 | $ 5,293 | $ 4,548 | 86% | 48% |
| 8 | KRT | $ 24,857 | $ 3,298 | $ 3,382 | 103% | 51% |
| 9 | KSP | $ 29,172 | $ 3,988 | $ 2,471 | 62% | 44% |
| 10 | KHK | $ 34,622 | $ 6,401 | $ 5,084 | 79% | 40% |
| 11 | OMC | $ 17,992 | $ 3,777 | $ 3,670 | 97% | 53% |
| 12 | MDK | $ 12,168 | $ 3,561 | $ 1,932 | 54% | 41% |
| 13 | PLN | $ 9,930 | $ 1,775 | $ 1,675 | 94% | 62% |
| 14 | PNP | $ 9,603 | $ 996 | $ 787 | 79% | 25% |
| 15 | PST | $ 10,412 | $ 2,666 | $ 2,051 | 77% | 48% |
| 16 | PVG | $ 32,788 | $ 5,438 | $ 5,382 | 99% | 50% |
| 17 | PVH | $ 17,944 | $ 4,085 | $ 2,409 | 59% | 31% |
| 18 | RTK | $ 18,868 | $ 3,916 | $ 3,732 | 95% | 43% |
| 19 | SRP | $ 26,352 | $ 4,237 | $ 3,310 | 78% | 34% |
| 20 | SHV | $ 15,898 | $ 2,525 | $ 1,489 | 59% | 37% |
| 21 | STG | $ 17,108 | $ 2,230 | $ 1,649 | 74% | 25% |
| 22 | SVR | $ 22,600 | $ 3,608 | $ 3,046 | 84% | 37% |
| 23 | TKV | $ 13,820 | $ 2,066 | $ 2,037 | 99% | 66% |
| **Total** | | **$ 503,011** | **$ 85,610** | **$ 67,786** | **79%** | **44%** |

**តារាងទី៩ : សង្ខេបថវិកាចំណាយ របស់ខេត្ត-ក្រុង ឧបត្ថម្ភដោយ GFATM-R1 PII**

| | Provinces | Annual | Q3 Plan | Q3 Actual | Q3% | A % |
|---|---|---|---|---|---|---|
| 1 | KCM | $ 44,844 | $ 15,026 | $ 7,114 | 47% | 73% |
| 2 | PLN | $ 10,069 | $ 2,509 | $ 905 | 36% | 66% |

| | | | | | | |
|---|---|---|---|---|---|---|
| 3 | PNP | $ 22,560 | $ 4,263 | $ 315 | 7% | 49% |
| 4 | PST | $ 14,924 | $ 3,076 | $ 606 | 20% | 55% |
| 5 | SHV | $ 17,704 | $ 2,491 | $ 2,466 | 99% | 44% |
| 6 | TKV | $ 15,497 | $ 1,925 | $ 630 | 33% | 52% |
| **Total** | | **$ 125,598** | **$ 46,562** | **$ 29,512** | **63%** | **50%** |

**តារាងទី៦ : សង្ខេបចរិកាចំណាយ របស់ខេត្ត-ក្រុង ឧបត្ថម្ភដោយ GFATM-R2 PII**

| | Provinces | Annual | Q3 Plan | Q3 Actual | Q3% | A % |
|---|---|---|---|---|---|---|
| 1 | BTB | $ 8,796 | $ 2,426 | $ 3,200 | 132% | 58% |
| 2 | KCN | $ 8,547 | $ 2,363 | $ 2,106 | 89% | 41% |
| 3 | KTM | $ 13,943 | $ 4,699 | $ 4,208 | 90% | 57% |
| 4 | KPT | $ 12,168 | $ 4,056 | $ 3,451 | 85% | 59% |
| 5 | KDL | $ 14,100 | $ 5,495 | $ 5,753 | 105% | 66% |
| 6 | KSP | $ 13,079 | $ 6,706 | $ 3,978 | 59% | 53% |
| 7 | PVG | $ 10,544 | $ 3,515 | $ 3,399 | 97% | 65% |
| 8 | SRP | $ 10,058 | $ 2,958 | $ 2,279 | 77% | 37% |
| 9 | SVR | $ 10,386 | $ 2,716 | $ 2,350 | 87% | 44% |
| **Total** | | **$ 101,621** | **$ 38,182** | **$ 24,196** | **88%** | **54%** |

**តារាងទី៧ : សង្ខេបចរិកាចំណាយ របស់ខេត្ត-ក្រុង ឧបត្ថម្ភដោយ EUROPAID**

| | Provinces | Annual | Q3 Plan | Q3 Actual | Q3% | A % |
|---|---|---|---|---|---|---|
| 1 | OD SPM / PST | $ 8,320 | $ 1,826 | $ 3,571 | 196% | 64% |
| 2 | OD Kirivong /TKV | $ 13,165 | $ 3,835 | $ 2,155 | 56% | 58% |

| | | | | | | |
|---|---|---|---|---|---|---|
| 3 | OD Ang Roka /TKV | $ 14,217 | $ 4,906 | $ 3,058 | 62% | 64% |
| **Total** | | **$ 35,702** | **$ 10,567** | **$ 8,784** | **83%** | **62%** |

**តារាងទី៨ : សង្ខេបថវិកាចំណាយ របស់ខេត្តបន្ទាយមានជ័យ ឧបត្ថម្ភដោយ CDC**

| Province | Annual | Q3 Plan | Q3 Actual | Q3% | A % |
|---|---|---|---|---|---|
| BMC | $ 268,943 | $ 35,081 | $ 46,027 | 131% | 56% |

# សេចក្តីសង្ខេប

នៅក្នុងត្រីមាសទី៣ ឆ្នាំ ២០០៦នេះ ថវិកាចំនួន ១,៤៣៧,២៦៧ ដុល្លាអាមេរិក ត្រូវបានចំណាយ គឺប្រហែលជា ៤៥% នៃគំរោងផែនការប្រចាំឆ្នាំ ដែលគ្រប់គ្រងដោយមជ្ឈមណ្ឌលជាតិ និងប្រហែល ៧៨% នៃគំរោងផែនការប្រចាំត្រីមាស ដើម្បីគាំទ្រដល់ការអនុវត្តន៏សកម្មភាព នៅថ្នាក់ជាតិ និងថ្នាក់ខេត្ត។

## ១. សកម្មភាពនៅថ្នាក់ខេត្ត

នៅក្នុងត្រីមាសទី៣ ឆ្នាំ ២០០៦ នេះ កម្មវិធីអេដស៍ ទាំង២៤ខេត្ត-ក្រុង ដែលឧបត្ថម្ភដោយគំរោង DFID, CDC, EUROPAID និងគំរោងមូលនិធិសកលជុំទី១ និងទី២ បានប្រើប្រាស់ថវិកាដែលបានអនុម័តហើយអស់ ៨៥%នៃគំរោងផែនការ ដើម្បីអនុវត្តសកម្មភាពបង្ការនិងទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ ដូចជាការអប់រំ ផ្សព្វផ្សាយតាមរយៈវិទ្យុ ទូរទស្សន៍ កម្មវិធីមិត្តអប់រំមិត្ត កម្មវិធីអប់រំផ្ទាល់ កម្មវិធីប្រើប្រាស់ស្រោមអនាម័យ១០០% ការងារគ្រប់គ្រង និងព្យាបាលជំងឺកាមរោគ សំរាប់ប្រជាជនទូទៅ នៅតាមមណ្ឌលសុខភាព ការងារគ្រប់គ្រង និងព្យាបាលជំងឺកាមរោគ សំរាប់នារីរកស៊ីផ្លូវភេទ នៅគ្លីនិកកាមរោគទាំង ២៩, កម្មវិធីថែទាំបន្ត ដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ និងការងារគ្រប់គ្រង និងសំរបសំរួលជាដើម។

## ២. សកម្មភាពនៅថ្នាក់ជាតិ

ដើម្បីពង្រឹងការអនុវត្តន៏សកម្មភាពទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានអនុវត្តន៏នូវសកម្មភាពមួយចំនួនដូចជា:

### ១. ការអប់រំផ្សព្វផ្សាយ និងកម្មវិធីប្រើប្រាស់ស្រោមអនាម័យ១០០%:

ដើម្បីឆ្លើយតបទៅនឹងតំរូវការសំភារៈអប់រំស្តីពីជំងឺអេដស៍/កាមរោគ សំរាប់ប្រើប្រាស់ក្នុងសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ សំរាប់យុទ្ធនាការផ្សព្វផ្សាយនៅក្នុងឱកាសបុណ្យអុំទូក និងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ មជ្ឈមណ្ឌលជាតិ បានផលិតសំភារៈមួយចំនួនដូចជា: មួកចំនួន ៦០០០ និងអាវយឺតចំនួន ៦០០០ ដើម្បីធ្វើការបែងចែកដល់ខេត្ត-ក្រុង និងអង្គការផ្សេងៗ។

ដើម្បីពង្រឹងនូវសមត្ថភាពបន្ថែមដល់ក្រុមការងារអប់រំផ្ទាល់/មិត្តអប់រំមិត្ត និងកម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០% នៅថ្នាក់ខេត្ត មជ្ឈមណ្ឌលជាតិ សហការជាមួយក្រុមការងារបច្ចេកថ្នាក់ជាតិ បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីកម្មវិធីមិត្តអប់រំមិត្ត កម្មវិធីអប់រំផ្ទាល់ ចំនួន២វគ្គ។

មន្ត្រីផ្នែកនេះ ក៏បានចុះអភិបាលការងារលើកម្មវិធីមិត្តអប់រំមិត្ត កម្មវិធីអប់រំផ្ទាល់ និងកម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១00% ការបែងចែក និងការប្រើប្រាស់សំភារៈអប់រំ នៅតាមបណ្តាខេត្តមួយចំនួនដូចជាៈ កំពង់ស្ពឺ,ក្រុងព្រះសីហនុ,កំពង់ចាម,ក្រចេះ ដើម្បីឱ្យការអនុវត្តកម្មវិធីនេះមានដំណើរការកាន់តែល្អប្រសើរឡើង។

## ២. កម្មវិធីជំងឺកាមរោគ

ដើម្បីឱ្យការអនុវត្តកម្មវិធីនេះកាន់តែមានភាពប្រសើរ មន្ត្រីផ្នែកជំងឺកាមរោគ បានរៀបចំកិច្ចប្រជុំជាមួយក្រុមការងារបច្ចេកទេស ដើម្បីរៀបចំកែលំអនូវ គោលនយោបាយ គោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រង និងថែទាំជំងឺកាមរោគ សំរាប់ប្រជាជនទូទៅ និង សំភារៈសំរាប់បណ្តុះបណ្តាល ។

ដោយសហការជាមួយផ្នែក BCC ផ្នែកនេះបានរៀបចំកិច្ចប្រជុំសំរបសំរួលរវាងកម្មអប់រំផ្ទាល់ ស្រោមអនាម័យ១00% និងការព្យាបាលជំងឺកាមរោគដល់នារីរកស៊ីផ្លូវភេទ ដោយមានការចូលរួមពី ប្រធានកម្មវិធីអេដស៍ មន្ត្រីគ្លីនិកកាមរោគ និងក្រុមការងារអប់រំផ្ទាល់ ទាំង ២៤ ខេត្ត-ក្រុង។

ផ្នែកនេះក៏បានចុះអភិបាល ការងារនៅតាម គ្លីនិកកាមរោគ និងមណ្ឌលសុខភាព ដែលមានសេវាថែទាំជំងឺកាមរោគ នៅតាមបណ្តាខេត្ត មួយចំនួនដូចជាៈ កំពង់ចាម ក្រចេះ កំពង់ស្ពឺ ក្រុងព្រះសីហនុ។

## ៣. កម្មវិធីថែទាំអ្នកជំងឺអេដស៍បន្ត

រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការព្យាបាល អ្នកជំងឺអេដស៍ ដោយប្រើឱសថឱកាសនិយម និង ឱសថប្រឆាំងមេរោគ អេដស៍ ជំនាន់ទី ៥ ដល់ក្រុមគ្រូពេទ្យ ដែលមកពី ១៧ខេត្ត-ក្រុង និងវគ្គបណ្តុះបណ្តាលស្តីពីផ្តល់ប្រឹក្សា ក្នុងការព្យាបាល ដោយប្រើឱសថឱកាសនិយម និង ឱសថប្រឆាំងមេរោគអេដស៍ ជំនាន់ទី ៤ ដល់គិលានុបដ្ឋាក និងគិលានុបដ្ឋាយិកា។

ដោយមានកិច្ចសហការជាមួយមជ្ឈមណ្ឌលកំចាត់រោគរបេង រៀបចំវគ្គសិក្ខាសាលាតំរង់ទិស ស្តីពីសកម្មភាពសហការរបេង /អេដស៍ ដល់មន្ត្រីសុខាភិបាលមកពីមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក នៅមន្ទីរសុខាភិបាលខេត្តកំពត និងក្រុងព្រះសីហនុ។

វគ្គសិក្ខាសាលា ស្តីពីការផ្តល់ប្រឹក្សា និងបច្ចេកទេសមន្ទីរពិសោធន៍ ដល់មន្ត្រីផ្នែកផ្តល់ប្រឹក្សានិង ធ្វើតេស្តឈាម មកពីខេត្ត-ក្រុង ចំនួន ១៧។

មន្ត្រីផ្នែកនេះ ក៏បានចុះអភិបាល និងផ្តល់ជំនួយបច្ចេកទេសលើការងារផ្តល់ប្រឹក្សា ធ្វើតេស្តឈាមការថែទាំ អ្នកជំងឺអេដស៍តាមផ្ទះ ការថែទាំនៅក្នុងមន្ទីរពេទ្យ និងការថែទាំបន្ត នៅតាមបណ្តាខេត្ត មួយចំនួនដូចជានៅព្រៃវែង បាត់ដំបង ពោធិសាត់ កណ្តាល និងកំពត។

### ៤. ផ្នែកអង្កេតតាមដាន និង ស្រាវជ្រាវ

រៀបចំកិច្ចប្រជុំសំរបសំរួល ដើម្បីពិភាក្សា និងផ្តល់យោបល់លើ ពិធីសារ ទំរង់ សំរាប់ការអង្កេតអត្រាប្រេវ៉ាឡង់មេរោគអេដស៍ឆ្នាំ២០០៦ និងកិច្ចប្រជុំផ្សព្វផ្សាយលទ្ធផលស្តីពីការអង្កេតអត្រាប្រេវ៉ាឡង់ជំងឺកាមរោគឆ្នាំ ២០០៥ នៅ សណ្ឋាគារភ្នំពេញ។

ដោយមានការសហការជាមួយវិទ្យាស្ថានជាតិស្រាវជ្រាវផ្នែកគ្លីនិក និងអេពីដេមីសាស្ត្រនៃជំងឺអេដស៍ និងសកលវិទ្យាល័យញូសោតវេល ប្រទេសអូស្រ្តាលី និងដោយមានជំនួយឧបត្ថម្ភរបស់ក្រុមហ៊ុន Roche មជ្ឈមណ្ឌលជាតិបានរៀបចំសន្និសិទ្ធ ស្តីពីការព្យាបាល និងការថែទាំជំងឺអេដស៍លើកទី១នៅភ្នំពេញ ដែលមានអ្នកចូលរួមចំនួន៤១៥នាក់ មកពីមន្ទីរពេទ្យបង្អែក អង្គការនានា និងដៃគូការងារផ្សេងៗទៀតមកពី ២៤ខេត្ត-ក្រុង។ គោលបំណងនៃសន្និសិទ្ធនេះគឺ ដើម្បីចែករំលែក និងផ្លាស់ប្តូរបទពិសោធន៍ ក្នុងការព្យាបាលនិងថែទាំជំងឺអេដស៍ ដើម្បីលើកកំពស់ និងបង្កើនចំណេះដឹង ដល់ផ្តល់សេវា ក្រុមគ្រូពេទ្យ អ្នកផ្តល់ប្រឹក្សា និងអ្នកបច្ចេកទេសមន្ទីរពិសោធន៍។

### ៥. ការងារគ្រប់គ្រង សំរបសំរួលកម្មវិធី និង ផែនការ

មជ្ឈមណ្ឌលជាតិបានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការងារគ្រប់គ្រងកម្មវិធីអេដស៍-កាមរោគ ដល់អ្នកសំរបសំរួលកម្មវិធីអេដស៍នៅថ្នាក់ស្រុកប្រតិបត្តិ ដែលមកពីស្រុកប្រតិបត្តិចំនួន ១៨។

រៀបចំវគ្គសិក្ខាសាលា ស្តីពីការពិនិត្យឡើងវិញនូវ បែបបទក្នុងការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តតាមស្នាដៃការងារដល់កម្មវិធីអេដស៍ខេត្ត-ក្រុង ដែលមានអ្នកចូលរួមចំនួន៥២នាក់មកពី២០ខេត្ត-ក្រុង និងផ្នែកនានានៃមជ្ឈមណ្ឌលជាតិ ។ គោលបំណងនៃវគ្គសិក្ខាសាលានេះ គឺដើម្បីណែនាំនូវ បែបបទក្នុងការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តតាមស្នាដៃការងារ របស់មជ្ឈមណ្ឌលជាតិ ទំរង់បន្ថែមថ្មីខ្លះៗ ។

ផ្នែកគ្រប់គ្រងទិន្នន័យ បានចុះបញ្ចូលនូវកម្មវិធី database របស់ VCCT និង STD ថ្មី ដែលទើបនឹងរៀបចំរួច និងបង្រៀនពី របៀបបញ្ចូល និងទុកដាក់ទិន្នន័យ នៅតាមមណ្ឌលធ្វើតេស្តឈាម និងគ្លីនិកកាមរោគ

នៅខេត្តកំពង់ស្ពឺ, កោះកុង, ក្រុងព្រះសីហនុ, តាកែវ, កំពត, បាត់ដំបង,បន្ទាយមានជ័យ, ប៉ៃលិន, ស្វាយរៀង, ព្រៃវែង, កំពង់ចាម,ក្រចេះ, កំពង់ធំ, សៀមរាប។

ផ្នែកគ្រប់គ្រងឱសថ សំភារៈ និងបរិក្ខា បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងឱសថជំងឺឱកាសនិយម និងឱសថប្រឆាំងមេរោគអេដស៍ ដល់ឱសថការី នៅថ្នាក់ស្រុកប្រតិបត្តិ ចំនួន ២វគ្គ និង វគ្គបណ្តុះបណ្តាលបំប៉ន ស្តីពីការគ្រប់គ្រងឱសថ និងសំភារៈបរិក្ខា ជំងឺកាមរោគ ដល់មន្ត្រីគ្រប់គ្រងឱសថនៅគ្លីនិកកាមរោគ និងស្រុកប្រតិបត្តិ ចំនួន ២វគ្គដែរ។

ដើម្បីពង្រឹងការអនុវត្តសកម្មភាពនូវថ្នាក់ខេត្ត មន្ត្រីផ្នែកផែនការ តាមដាន និងរបាយការណ៍, ផ្នែកគ្រប់គ្រងឱសថ សំភារៈ បរិក្ខា និង ផ្នែកហិរញ្ញកិច្ច បានចុះធ្វើការអភិបាល នៅតាមបណ្តាខេត្ត-ក្រុងមួយចំនួន ដូចជា នៅខេត្តកណ្តាល រាជធានីភ្នំពេញ, ឧត្តរមានជ័យ, សៀមរាប, ប៉ៃលិន។

បានចងក្រងនូវគំរោងផែនការសកម្មភាពគ្រប់ជ្រុងជ្រោយ ប្រចាំត្រីមាសទី៣ , និងរបាយការណ៍គ្រប់ជ្រុងជ្រោយប្រចាំត្រីមាស ជាភាសាខ្មែរ និងអង់គ្លេស និងធ្វើការថតចំលង ចំនួន៤៥០ច្បាប់ដើម្បីបែងចែកដល់ម្ចាស់ជំនួយ មន្ទីរសុខាភិបាលខេត្ត ស្រុកប្រតិបត្តិ និងស្ថាប័ន អង្គការផ្សេងៗ ដែលពាក់ព័ន្ធ។